DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

ទីក្រុង ម៉ានីឡា, ថ្ងៃទី ២០ កញ្ញា ២០១១

# សេចក្តីប្រកាសព័ត៌មាន

## វត្តមានរបស់មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន មកពីប្រទេសទាំង៥ ដែលជាសមាជិកអាស៊ាន ពិភាក្សាស្តីពី បទពិសោធន៍ល្អៗ ក្នុងការងារអភិបាលកិច្ចមូលដ្ឋាន

សមាជឆ្លងប្រទេសលើកទីបីនៃគម្រោង ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិប-តេយ្យ នៅអាស៊ីអាគ្នេយ៍ (DELGOSEA) ជាគម្រោងថ្នាក់តំបន់ជួយគាំទ្រដល់ការផ្លាស់ប្តូរបទពិសោធន៍ល្អ ក្នុងការងារអភិបាលកិច្ចមូលដ្ឋាន នឹងត្រូវប្រព្រឹត្តិទៅចំនួនពីរថ្ងៃ គឺនៅថ្ងៃទី ២៧ ដល់ ២៨ ខែ កញ្ញា ឆ្នាំ២០១១ នៅទីក្រុង បាតាំ ប្រទេសឥណ្ឌូនេស៊ី។ កិច្ចប្រជុំនេះនឹងមានបញ្ចូលវគ្គសិក្ខាសាលាបណ្តុះបណ្តាលចំនួន១ថ្ងៃ ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ។ គម្រោង DELGOSEA ត្រូវបានផ្តល់សហមូលនិធិ ពីសហភាពអឺរ៉ុប (EC) និង ខុនរាដ អាដេណៃ ស៊្ទីហទុង (KAS) នៃប្រទេសអាល្លឺម៉ង់ តាមរយៈក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍របស់ប្រទេសអាល្លឺម៉ង់។

កិច្ចប្រជុំនេះនឹងមានអ្នកចូលរួម មកពីបណ្តាក្រុងសាកល្បងចំនួន ១៦ ក្នុងប្រទេសដែលជាដៃគូទាំង៥ ព្រមទាំងវត្តមាននៃតំណាងសមាគមរដ្ឋាភិបាលមូលដ្ឋាន មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន អង្គការសង្គមស៊ីវិល វិទ្យាស្ថានអប់រំ និងបណ្តាញសារព័ត៌មាននានា។ ក្រៅពីវត្តមានសំខាន់ៗនៃអ្នកចូលរួមមកពី ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីតំណាងសហភាពអឺរ៉ុប **លោក អេរីក ហាប័រ**

Konrad Adenauer Stiftung | UCLG ASPAC | LOCAL GOVERNMENT DEVELOPMENT FOUNDATION

*A project implemented by the contractor*

*Konrad-Adenauer-Stiftung e.V. Head Office Germany*

*Field office Philippines 5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines*

*This project is co-funded by the European Union*

*Delegation of the European Union to Indonesia and Brunei Darussalam Intiland Tower, 16th floor Jl Jend Sudirman 32 Jakarta 10220 Indonesia Tel: (62 21) 2554 6200 Fax:(62 21) 2554 6201*

*www.delgosea.eu*

*The European Commission is the EU's executive body.*

*The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.*

ទីក្រុង ម៉ានីឡា, ថ្ងៃទី ២០ កញ្ញា ២០១១

អ្នកផ្តល់ប្រឹក្សាយោបល់ទីមួយ និង **អ្នកស្រី ណូរីយ៉ាន់ទី មាណូរ៉ុង** មន្ត្រីគម្រោង ដែលជាគណៈប្រតិភូនៃសហភាពអឺរ៉ុប ប្រចាំប្រទេសឥណ្ឌូនេស៊ី ព្រុយណេ និង ដារ៉ូសាលាម។ ដៃគូអនុវត្តគម្រោង រួមមាន សមាគមនៃទីក្រុងវៀតណាម(ACVN) មូលនិធិអភិវឌ្ឍន៍រដ្ឋាភិបាលមូលដ្ឋាននៃប្រទេសហ្វីលីពីន (LOGODEF) សម្ព័ន្ធភាពជាតិឃុំសង្កាត់នៃប្រទេសកម្ពុជា (NLC/S) វិទ្យាស្ថានបរិស្ថាននៃប្រទេសថៃ (TEI) សហព័ន្ធទីក្រុង និងរដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក (UCLG ASPAC) មានក្តីរំភើបជាមួយនឹងឱកាសដើម្បីពង្រឹងបណ្តាញការងាររបស់ខ្លួន ។

កិច្ចប្រជុំដែលមានរយៈពេលពីរថ្ងៃនេះត្រូវបានចែកចេញជាពីរវគ្គ ក្នុងនោះវគ្គទីមួយគឺ ការពិនិត្យសមាជពាក់កណ្តាលត្រីមាសទាំងមូលឡើងវិញ ការវាយតំលៃ និង មេរៀនបទពិសោធន៍ ហើយវគ្គទីពីរ នឹងត្រូវពិនិត្យមើលលើបញ្ហានិរន្តភាពគម្រោង។

កម្មវិធីនេះនឹងមានបញ្ចូលវគ្គស្តីពី Market Place ដែលជាវគ្គមួយតម្រូវឱ្យទីក្រុងសាកល្បងទាំង១៦ បង្ហាញពីគម្រោងរបស់ខ្លួន ក៏ដូចជាការបើកឱកាសឱ្យអ្នកសារព័ត៌មានធ្វើការសាកសួរ និងការពិភាក្សាតុមូល ស្តីពីការប្រមើលមើលយ៉ាងលម្អិតលើបញ្ហាប្រឈមនានា នៅក្នុងដំណើរការនៃការអនុវត្តន៍នូវអភិបាលកិច្ចល្អមូលដ្ឋាន ដែលមានរួចជាស្រេចនៅក្នុងទីក្រុងសាមីនីមួយៗ។ សមាគមរដ្ឋាភិបាលជាច្រើន ដែលមកពីបណ្តាប្រទេសជាដៃគូទាំង៥ និងអ្នកពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការអនុវត្ត ក៏នឹងត្រូវធ្វើការបញ្ចេញទស្សនៈ និងគំនិតយោបល់ ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន នាពេលកន្លមមកផងដែរ ។ មន្ត្រីរដ្ឋាភិបាលដែលត្រូវបានអញ្ជើញមកចូលរួម នឹងធ្វើការបង្ហាញពីផែនការរបស់ខ្លួន និងគំនិតផ្តួចផ្តើមដើម្បីធ្វើឱ្យមានភាពប្រសើរឡើងលើការងារអភិបាលកិច្ចមូលដ្ឋាន

DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

ទីក្រុង ម៉ានីឡា, ថ្ងៃទី ២០ កញ្ញា ២០១១

ហើយស្របពេលគ្នានេះ ត្រូវផ្តល់នូវអនុសាសន៍ដំបូង លើឯកសារអនុសាសន៍ស្តីពីគោលនយោបាយរបស់គម្រោង DELGOSEA ។

ការផ្ទៀងផ្ទាត់ដ៏សមស្រប រវាងបទពិសោធន៍ការងារកន្លងមក និងការត្រៀមខ្លួនសម្រាប់ពេលអនាគត នឹងស្តែងឱ្យឃើញពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលគម្រោង និងការផ្តល់សំណូមពរដើម្បីអនុវត្តបន្ត ដោយផ្អែកលើបទពិសោធន៍ដែលបានអនុវត្តកន្លងមក ។

**លោក ភីធ័រ** ប្រធានគម្រោងនៅ KAS បានមានប្រសាសន៍ថា "នេះគឺជាពេលវេលាដែលគួរឱ្យរំភើបមួយនៅក្នុងជីវិតនៃគម្រោង DELGOSEA" "មូលនិធិត្រូវបានផ្តល់ជាមូលដ្ឋានគ្រឹះ រីឯអ្នកអនុវត្តគឺមន្ត្រីនៅក្នុងបណ្តាទីក្រុងសាកល្បងទាំងអស់ដែលត្រូវបន្តការងាររបស់ខ្លួន និងឈានដល់ដំណាក់កាលអនុវត្តជាក់ស្តែង ។

កិច្ចប្រជុំនេះបង្ហាញពីឱកាសដ៏វិសេសវិសាល ដើម្បីឱ្យបានជួបជុំគ្នា និងទទួលយកបទពិសោធន៍ ព្រមទាំងមើលពីអ្វីដែលនឹងកើតឡើងបន្ទាប់ទៀត ក៏ដូចជាវិធីសាស្ត្រដែលយើងអាចឈានទៅរកនិរន្តភាពលើការងារអភិបាលកិច្ចល្អមូលដ្ឋាន បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ។

---